# សិក្ខាសាលាស្តីពី

ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ
នឹងការអនុវត្តមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
ទន្លេបាសាក់២ ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧

## គោលការណ៍ណែនាំបច្ចេកទេសស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន





រៀបចំដោយ៖
លោក ដែក វិមានរស្មី អនុប្រធាននាយកដ្ឋានគ្រប់គ្រងសំណល់រឹង
នាយកដ្ឋានគ្រប់គ្រងសំណល់រឹង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន ក្រសួងបរិស្ថាន

## មាតិកា

១. ស្ថានភាពទូទៅ
២. ការគ្រប់គ្រងសំរាម សំណល់រឹងនៅទីក្រុងភ្នំពេញ
៣. ផលប៉ះពាល់នៃការគ្រប់គ្រងសំរាម សំណល់រឹង
៤. បញ្ហាប្រឈមក្នុងការគ្រប់គ្រងសំរាម សំណល់រឹង
៥. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹង
៦. គោលការណ៍ណែនាំបច្ចេកទេសស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹង

2

## តើសំរាម សំណល់រឹងទីប្រជុំជនជាអ្វី?

យោងអនុក្រឹត្យលេខ ១១៣ អនក្រ.បក

- **សំរាម** សំដៅដល់របស់របរប្រើប្រាស់ សម្ភារៈ ផលិតផលដែលបានបន្សល់ ឬបង្កើតពីជីវភាពផ្ទាល់របស់មនុស្សប្រចាំថ្ងៃ ដែលមិនមានផ្ទុកសារជាតុពុល ឬសំណល់គ្រោះថ្នាក់។
- **សំណល់រឹងទីប្រជុំជន** សំដៅដល់សំណល់រឹងដែលបានបន្សល់ ឬបង្កើតពីសកម្មភាពអាជីវកម្ម ឬសេវាកម្មដែលមិនមានផ្ទុកសារជាតុ ឬសំណល់គ្រោះថ្នាក់។
- **សំណល់គ្រោះថ្នាក់** សំដៅដល់វត្ថុធាតុរឹងរាវ ឧស្ម័ន សារជាតុវិទ្យុសកម្ម សារជាតុផ្ទុះ សារជាតុឆេះ សារជាតុចម្លងជំងឺ.....ដែលបង្កគ្រោះថ្នាក់ដល់មនុស្ស សត្វ រុក្ខជាតិ និងបរិស្ថាន។

3

## ១. ស្ថានភាពទូទៅ

- ការកើនឡើងនូវចំនួនប្រជាជនក្នុងទីក្រុង ពីមួយឆ្នាំទៅមួយឆ្នាំ
- ការកើនឡើងនៃសេដ្ឋកិច្ចជាតិ (ទេសចរណ៍ សំណង់ និងឧស្សាហកម្ម...)
- ការទុកដាក់សំរាម សំណល់រឹងរបស់ប្រជាពលរដ្ឋមួយចំនួនមិនទាន់បានត្រឹមត្រូវ (ការវេចខ្ចប់ ការញែក)
- សេវាកម្មប្រមូលសំរាម មិនទាន់បានគ្របដណ្ដប់គ្រប់ទីកន្លែង និងមិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស (ការស្តុកទុក ការដឹកជញ្ជូន...)





4

## សំរាម សំណល់រឹងទីប្រជុំជន ដែលបានចាក់នៅលានចាក់សំរាមទូទាំងប្រទេស តោន/ឆ្នាំ




ប្រភព៖ MoE, 2017

5

## ក្រាហ្វិកប្រៀបធៀបសំណល់ដែលបានបោះចោលនៅទីលាន និងសំណល់ដែលបានធ្វើការកែច្នៃ តោន/ឆ្នាំ




ប្រភព៖ MoE, 2017

6

## យន្តការនៃការគ្រប់គ្រងសំរាម សំណល់រឹងនៅកម្ពុជា




7

## សកម្មភាពធ្វើជីកំប៉ុស្ត



## សកម្មភាពកែច្នៃ




## កន្លែងប្រមូលទិញអេតចាយ



## ២. ការគ្រប់គ្រងសំរាម សំណល់រឹងនៅទីក្រុងភ្នំពេញ

- ទីលានចាក់សំរាមនៅដង្កោ ដែលបានបើកដំណើរការចាប់តាំងពីឆ្នាំ ២០០៩
- មានចំងាយប្រមាណ ១៥ គ.ម ពីទីប្រជុំជនរាជធានីភ្នំពេញ
- ទីលានចាក់សំរាមនេះ បានរៀបចំឡើងដែលអាចទទួលចាក់សំរាមរហូតដល់ឆ្នាំ ២០៣៣ ប៉ុន្តែតាមការប៉ាន់ស្មាន ទីលាននេះនឹងពេញនៅឆ្នាំ ២០២០
- ដោយការកើនឡើងសំណល់ពីមួយថ្ងៃទៅមួយថ្ងៃ ដូច្នេះទីលានចាក់សំរាមនេះពេញមុនការរំពឹងទុកចំនួន ១៣ឆ្នាំ



## បរិមាណសំណល់ដែលបានបញ្ចេញទៅទីលាន នៅទីក្រុងភ្នំពេញ




12

## សមាសសភាគសំរាម សំណល់រឹងនៅរាជធានីភ្នំពេញ




13

## ៣. ផលប៉ះពាល់នៃការគ្រប់គ្រងសំរាម និងសុខភាព

- ជាប្រភព និងទីជម្រកនៃពពួកមេរោគឆ្លង ព្រមទាំងសត្វល្អិតចង្រៃជាច្រើន
- ធ្វើឱ្យបាត់បង់សោភ័ណភាពទីក្រុង និងលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ
- បង្កឱ្យមានក្លិនស្អុយប៉ះពាល់ដល់អ្នករស់នៅ ក្បែរ និងបរិស្ថានជុំវិញ
- ជះឥទ្ធិពលអាក្រក់ដល់សុខភាពប្រជាជន ដូចជាប៉ះពាល់ដល់ផ្លូវដង្ហើម កើតមានជម្ងឺសើស្បែក និងបណ្តាលឱ្យកើតមានជម្ងឺរ៉ាំរ៉ៃផ្សេងៗ





- ដាជម្រកដល់ភ្នាក់ងារចម្លងជម្ងឺមួយចំនួនធំ និងមួយផ្នែកទៀតដែលផ្ទុកទៅដោយសារធាតុគីមីពុល អាចជ្រាបចូលទៅក្នុងដី បានធ្វើឱ្យប៉ះពាល់ដល់គុណភាពដី ទឹក និងទឹកក្រោមដី ។ ចំណែកឯសារធាតុមួយចំនួនដែលមិនអាចបំបែកធាតុបាន ដូចជាកៅស៊ូ ប្លាស្ទិក កែវ។ល។
- ការបោះចោលសំណល់រាយប៉ាយ អាចបង្កស្ទះដល់ប្រព័ន្ធលូសាធារណៈ តាមរយៈការហូរនាំដោយទឹកភ្លៀងខូចដល់ សោភ័ណ និងសណ្តាប់ធ្នាប់សាធារណៈ។





15

## ការទុកដាក់សំរាម សំណល់រឹងទីប្រជុំជន



16

## ការទុកដាក់សំរាម សំណល់រឹងទីប្រជុំជន



## ៤. បញ្ហាប្រឈមក្នុងការគ្រប់គ្រងសំរាម សំណល់រឹង

- មិនមានការញែកនៅប្រភពបង្កើតសំណល់ គឺជាឧបសគ្គចម្បងដល់សកម្មភាពកែច្នៃសំណល់ ដែលជាយន្តការសំខាន់ក្នុងដំណើរឆ្ពោះទៅកាត់បន្ថយសំណល់ដែលត្រូវបោះចោលនៅទីលាន
- ពេលវេលានៃការបញ្ចេញសំណល់ពុំមានកាលវិភាគច្បាស់លាស់
- ការចូលរួមពីអ្នកបង្កើតសំណល់ (បង់ថ្លៃសេវា)
- ក្រុមហ៊ុនផ្តល់សេវាប្រមូល និងដឹកជញ្ជូន
- ទីលានចាក់សំរាម សំណល់រឹងទ្រីជុំជន (បញ្ហាដីធ្លី បច្ចេកទេស និងការងារគ្រប់គ្រង)

18

## ៥. លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសំណល់រឹង

- អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ២៧ មេសា ១៩៩៩ ស្តីពី ការគ្រប់គ្រងសំណល់រឹង
- អនុក្រឹត្យលេខ ១១៣អនក្រ.បក ចុះថ្ងៃទី ២៧ សីហា ២០១៥ ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- សារាចរអន្តរក្រសួងលេខ ១០៧០ ស.ជ.ណ បស្ត ស្តីពី ការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ប្រកាសអន្តរក្រសួងលេខ ៨០ ប្រក.មផ.បស្ត ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា

19

## ប្រតិបត្តិកម្មមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

អនុក្រឹត្យលេខ ១១៣អនក្រ.បក

ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១១៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

ទំព័រ ១/២០

គោលបំណងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម  សំណល់  រឹងទីប្រជុំជនប្រកបដោយ*ប្រសិទ្ធភាព  តម្លាភាព  និងគណនេយ្យភាព* ហើយបានដាក់ចេញនូវវិធានការណ៍សំខាន់ៗដូចជា៖

- ពង្រឹងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័ន អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធនានា
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឱ្យរដ្ឋបាលក្រុងស្រុក និងប្រតិភូកម្មមុខងារពីរដ្ឋបាលរាជធានី ទៅឱ្យរដ្ឋាលខណ្ឌ
- កំណត់វិធានការចាំបាច់ ដើម្បីបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពការគ្រប់គ្រង
- លើកកម្ពស់ការយល់ដឹងសាធារណៈ និងការចូលរួមរបស់ប្រជាពលរដ្ឋ

21

## ការគាំទ្រធនធានកញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន

- ឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ថវិកាចំនួន ៥០០០ លានរៀល ដល់ក្រុងទាំង២៦ នៅទូទាំងប្រទេស សម្រាប់បំពេញ ភាពខ្វះខាតដល់ការគ្រប់គ្រងសំណល់រឹង រាវ
- ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ថវិកាកើនឡើងដល់ ៨០០០ លានរៀល
- ឆ្នាំ២០១៧ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ថវិកាចំនួន ៨០០០ លានរៀល

22

# កញ្ចប់ថវិកាសេវាអនាម័យបរិស្ថាន ២០១៧

| រដ្ឋបាលក្រុង | ចំនួន(លានរៀល) |
|---|---|
| សិរីសោភ័ណ | ៤០៥ |
| ប៉ោយប៉ែត | ៤៤៧ |
| បាត់ដំបង | ៥៦១ |
| កំពង់ចាម | ២៦០ |
| កំពង់ឆ្នាំង | ២៦៧ |
| ច្បារមន | ២៨៥ |
| ស្ទឹងសែន | ៣០៧ |
| កំពត | ២៤៩ |
| តាខ្មៅ | ៣៥០ |
| ខេមរភូមិន្ទ | ២៣០ |
| ក្រចេះ | ២៣៨ |
| សែនមនោរម្យ | ១៩២ |
| ព្រះវិហារ | ២១៤ |

| រដ្ឋបាលក្រុង | ចំនួន(លានរៀល) |
|---|---|
| ព្រៃវែង | ២២២ |
| ពោធិ៍សាត់ | ៣៣១ |
| បានលុង | ២៣៥ |
| សៀមរាប | ៧៨៣ |
| ព្រះសីហនុ | ៣៦១ |
| ស្ទឹងត្រែង | ២៣៦ |
| ស្វាយរៀង | ២៧៨ |
| បាវិត | ២៥៩ |
| ដូនកែវ | ២៧១ |
| សំរោង | ៣២០ |
| កែប | ២០៩ |
| ប៉ៃលិន | ២៥២ |
| ស្ទួង | ២៥២ |



# ធុងសំរាមដែលដាក់តាមសាធារណៈ



## ការផ្សព្វផ្សាយអប់រំបរិស្ថាន





25

## ការផ្សព្វផ្សាយអប់រំបរិស្ថាន





## យុទ្ធនាការអនាម័យបរិស្ថាន





27

## ការសំអាតអនាម័យបរិស្ថាន





28

## ការសំអាតអនាម័យបរិស្ថាន



# ៦. គោលការណ៍ណែនាំបច្ចេកទេស ស្តីពី ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

30

- គោលការណ៍ណែនាំបច្ចេកទេសនេះ កំណត់អំពីលក្ខណៈបច្ចេកទេសលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនសំខាន់ៗ ដូចជា៖
  - គោលការណ៍ទូទៅនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
  - គោលការណ៍ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ ការកែច្នៃ (3R) និងការទាញយកធនធាន
  - គោលការណ៍នៃការរៀបចំ និងគ្រប់គ្រងទីលាន
  - គោលការណ៍ទូទៅនៃការរៀបចំឡដុតសំរាម សំណល់រឹង។

31

## ក. គោលបំណង និងទិសដៅ

- បង្កើនប្រសិទ្ធភាព និងសុវត្ថិភាពក្នុងការគ្រប់គ្រងសំរាម សំណល់រឹងនៅតាមទីប្រជុំជន ចាប់តាំងពីចំណុចបង្កើតដល់ការទុកសំណល់ចុងក្រោយនៅទីលាន
- ជំរុញការអនុវត្តគោលការណ៍ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃសំណល់រឹង (3R-Reduce Reuse Recycling)
- ជំរុញការទុកដាក់សំរាម សំណល់រឹង នៅទីលានឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស និងប្រកបដោយដោយសុវត្ថិភាពបរិស្ថាន
- ជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិរៀបចំផែនការក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ឱ្យបានសមស្របទៅនឹងតម្រូវការនិងស្ថានភាពជាក់ស្តែង ប្រកបដោយប្រសិទ្ធភាពខ្ពស់
- លើកកម្ពស់ការយល់ដឹងសាធារណៈ អំពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្នុងការចូលរួមចំណែកគាំពារបរិស្ថាននិងធនធានធម្មជាតិនានា។

32

## ខ. ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

➢ ការគ្រប់គ្រងសំរាម សំណល់រឹងប្រកបដោយសុវត្ថិភាពបរិស្ថាន ត្រូវគិតពីចំណុចចាប់ផ្តើមនៃការបង្កើតសំណល់ រហូតដល់ដំណាក់កាលទុកដាក់ចុងក្រោយនៅទីលាន។

➢ វដ្តនៃការគ្រប់គ្រងនេះ គឺចាប់ពីដំណាក់កាលនៃការបង្កើតសំណល់ ការទុកដាក់ និងការស្តុកបណ្តោះអាសន្ន ការប្រមូលនិងដឹកជញ្ជូន ការកែច្នៃ ការធ្វើប្រព្រឹត្តកម្ម និងការទុកដាក់ចុងក្រោយនៅទីលាន។

33

## គ. ការបង្កើតសំណល់

រដ្ឋបាលរាជធានី(ខណ្ឌ) ក្រុង ស្រុក មន្ទីរបរិស្ថាន ត្រូវជំរុញយន្តការកាត់បន្ថយការបង្កើតសំរាម សំណល់រឹងនៅនឹងប្រភពបង្កើត ដោយធ្វើការអប់រំ និងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋ ឬម្ចាស់សំណល់យល់ដឹង ផ្លាស់ប្តូរឥរិយាបទ និងចូលរួមសកម្មភាពកាត់បន្ថយការបង្កើតសំណល់ឱ្យអស់លទ្ធភាព ដូចជា៖

- កាត់បន្ថយការប្រើប្រាស់សម្ភារ ចំណីអាហារ និងរបស់របរផ្សេងៗលើសតម្រូវការ
- ប្រើប្រាស់សម្ភារដែលអាចប្រើបានច្រើនដង និងមិនបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន
- ប្រើប្រាស់ឡើងវិញនូវសម្ភារឱ្យអស់ពីលទ្ធភាព ឬផ្តល់ឱ្យអ្នកដ៏ទៃប្រើប្រាស់បន្ត
- កាត់បន្ថយការប្រើប្រាស់សម្ភារវេចខ្ចប់លើសតម្រូវការ ជាពិសេសថង់ប្លាស្ទិកស្រាលមានដៃយួរ ដោយដាក់បញ្ចូលទំនិញក្នុងថង់តែមួយ។

34

## ឃ. ការញែកសំណល់

ការញែកសំរាម សំណល់រឹងទីប្រជុំជនគួរធ្វើការញែកនិងបែងចែងជាប្រភេទដូចខាងក្រោម៖

- សំណល់សរីរាង្គ ដូចជា សំណល់ផ្ទះបាយ បន្លែ ផ្លែឈើ ជាដើម (ធុងសំរាមព៌ណបៃតង និងបិទស្លាកសញ្ញាសំគាល់)
- សំណល់ដែលអាចកែច្នៃបាន ដូចដបទឹកសុទ្ធ សំបកកំប៉ុងអាលុយមីញ៉ូម សំណល់ប្លាស្ទិក សំណល់លោហៈ សំណល់ក្រដាសផ្សេងៗ ជាដើម (ធុងសំរាមព៌ណខៀវ និងបិទស្លាកសញ្ញាសំគាល់)
- សំណល់ផ្សេងៗ (ធុងសំរាមព៌ណខ្មៅ និងបិទស្លាកសញ្ញាសំគាល់)

35

## ង. ការវេចខ្ចប់ ការទុកដាក់ និងការរៀបចំធុងសំរាម

រដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌត្រូវណែនាំប្រជាពលរដ្ឋ ឬម្ចាស់សំណល់ឱ្យធ្វើការវេចខ្ចប់ ទុកដាក់ទៅតាមប្រភេទសំណល់ដែលបានញែក ឲ្យបានត្រឹមត្រូវ ដោយៈ

- ម្ចាស់ ឬអ្នកបង្កើតសំរាម សំណល់រឹងត្រូវធ្វើការវេចខ្ចប់ ឬទុកដាក់ក្នុងធុងសំរាមផ្ទាល់ខ្លួននូវសំណល់តាមប្រភេទដាច់ដោយឡែកពីគ្នាប្រកបដោយសុវត្ថិភាព (មិនលេចធ្លាយ ឬជ្រាបទឹកសម្អុយ មិនជះក្លិនស្អុយដល់អ្នកដទៃ)
- សំណល់ដែលវេចខ្ចប់រួចនេះ ត្រូវរក្សាទុកនៅក្នុងទីតាំងណាមួយនៅក្នុងរបង ឬក្នុងផ្ទះ ដើម្បីរង់ចាំបញ្ចេញតាមពេលម៉ោងដែលបានកំណត់
- រដ្ឋបាលរាជធានី(ខណ្ឌ) ក្រុង ស្រុក និងអ្នកទទួលខុសត្រូវទីតាំងត្រូវរៀបចំឱ្យមានធុងសំរាមមានពណ៌និងស្លាកសញ្ញាសំគាល់តាមប្រភេទ ដោយមានទំហំសមស្រប និងចំនួនគ្រប់គ្រាន់ នៅតាមទីតាំងមួយចំនួន ដូចជាទីតាំងសាធារណៈ អគាររដ្ឋបាលសាធារណៈ មជ្ឈមណ្ឌលទេសចរណ៍ មជ្ឈមណ្ឌលពាណិជ្ជកម្ម សួនកំសាន្ត ជាដើម ។ល។

36

## ច. ការស្តុកទុកបណ្តោះអាសន្ន

រដ្ឋបាលរាជធានីក្រុង ស្រុក ខណ្ឌអាចបង្កើតទីតាំងស្តុកបណ្តោះអាសន្នតាមភាពចាំបាច់ និងត្រូវគិតពិចារណាយ៉ាងយកចិត្តទុកដាក់ ដោយមានការពិគ្រោះយោបល់ជាមួយអង្គភាពពាក់ព័ន្ធ ប្រជាពលរដ្ឋដែលរស់នៅក្បែរទីតាំង។ ការបង្កើតទីតាំងស្តុកបណ្តោះអាសន្ន ត្រូវប្រតិបត្តិតាមចំណុចមួយចំនួនដូចខាងក្រោម៖

- ទីតាំងដែលជ្រើសរើសសម្រាប់រៀបចំធ្វើជាទីកន្លែងស្តុកបណ្តោះអាសន្ន មិនត្រូវប៉ះពាល់ដល់ការធ្វើចរាចរ ចិញ្ចើមផ្លូវអ្នកថ្មើរជើង សោភ័ណភាព តំបន់សំខាន់ៗជាដើម។ល។
- ទីតាំងស្តុកទុកបណ្តោះសន្ន ត្រូវរៀបចំឡើងឱ្យស្របតាមបទដ្ឋានបច្ចេកទេស ដោយមានគម្របបិទជិតមិនបង្កក្លិនស្អុយ ងាយស្រួលក្នុងការប្រមូលនិងដឹកជញ្ជូនចេញ និងត្រូវមានកម្មវិធីដឹកជញ្ជូនចេញឱ្យបានទៀងទាត់ជាប្រចាំ។
- ទីតាំងស្តុកទុកបណ្តោះអាសន្ន មិនត្រូវស្តុកសំណល់លើសពី១២ម៉ោងក្នុងមួយថ្ងៃ ដោយមានកំណត់ពេលវេលាច្បាស់លាស់ក្នុងការទទួលសំណល់និងដឹកជញ្ជូនចេញ និងគួរអនុវត្តនៅពេលវេលាយប់ ឬពេលវេលាដែលមិនមានចរាចរមមាញឹក។

37

## ឆ. ស្ថានីយ៍ផ្ទេរសំណល់

ប្រតិបត្តិករ ឬរដ្ឋបាលរាជធានី ក្រុង ស្រុក ខណ្ឌគួរពិចារណាក្នុងការរៀបចំស្ថានីយ៍ផ្ទេរសំណល់ ក្នុងករណីដែលទីលានទុកដាក់សំណល់ស្ថិតនៅឆ្ងាយលើសពី១៥គម ដើម្បីកាត់បន្ថយការចំណាយនិងពេលវេលាលើការដឹកជញ្ជូន។ ការរៀបចំស្ថានីយ៍ផ្ទេរសំណល់ត្រូវយកចិត្តទុកដាក់អនុវត្តតាមវិធានមួយចំនួនដូចខាងក្រោម៖

- ត្រូវជ្រើសរើសទីតាំងសមស្រប ស្ថិតនៅឆ្ងាយពីតំបន់ដែលមានលំនៅឋានច្រើន ចៀសវាងការសាយភាយក្លិន ឬជាតំបន់ដែលមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ មិនបង្កការស្ទះចរាចរ មិននៅជាប់នឹងប្រភពទឹកធម្មជាតិ មិននៅជាប់នឹងសាលារៀននិងមន្ទីរពេទ្យ ជាដើម។ល។
- ត្រូវមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់និងសមស្រប និងមានវិធានការច្បាស់លាស់ ដើម្បីការការពារ និងទប់ស្កាត់ការប៉ះពាល់សុខភាពសាធារណៈ និងបរិស្ថានដែលអាចចេញពីប្រតិបត្តិការផ្ទេរសំណល់នេះ ដូចជា បញ្ហាក្លិន បញ្ហាទឹកស្អុយចេញពីសំណល់ ការហើររាយប៉ាយនៃសំណល់ បញ្ហាសត្វល្អិត បញ្ហាសំឡេងក្នុងពេលដំណើការគ្រឿងចក្រ ហើយនៅជុំវិញស្ថានីយ៍ផ្ទេរសំណល់នេះ បើអាចគួរត្រូវដាំដើមឈើ ដើម្បីស្រូប ឬកាត់បន្ថយការសាយភាយក្លិនស្អុយ ឬសត្វល្អិត ដែលអាចសាយភាយប៉ះពាល់ដល់តំបន់ជុំវិញ។
- ប្រតិបត្តិការផ្ទេរសំណល់នៅស្ថានីយ៍ ត្រូវមានកម្មវិធីច្បាស់លាស់ជៀសវាងការរំខានផ្សេងដល់សាធារណជន ។

38

## ៥. ការធ្វើជីកំប៉ុស្តិ៍

- ជីកំប៉ុស្តិ៍គឺជាផលិតផល ដែលផលិតចេញពីសំរាម សំណល់រឹងសរីរាង្គ ក្រោមអំពើបំបែកជាតុក្នុងលក្ខខណ្ឌមានអុកស៊ីសែន (Aerobic) និង គ្មានអុកស៊ីសែន (Anaerobic)
- ការអនុវត្ត និងទំហំបរិមាណនៃដំណើរការផលិត។ នៅកម្ពុជា សំរាម សំណល់រឹងមានសមាសភាគប្រមាណពី ៦០% ទៅ ៧០% ជា ប្រភេទសំណល់សរីរាង្គដែលងាយបំបែកជាតុ
- ជាជម្រើសដ៏ល្អ ក្នុងការសម្រេចចិត្តជ្រើសរើសវិធីសាស្ត្រការធ្វើជីកំប៉ុស្តិ៍ ក្នុងការកាត់បន្ថយសំរាម សំណល់រឹងទីប្រជុំជនដែលត្រូវបោះចោល ចុងក្រោយ ជាមួយនឹងការបង្កើតបានជាផលិតផលជីដែលមានគុណភាព សម្រាប់ដំណាំកសិកម្ម។

39

គោលបំណងនៃការផលិតជីកំប៉ុស្តិ៍ គឺដើម្បីកាត់បន្ថយបរិមាណសំណល់ បង្កើន អាយុកាលប្រើប្រាស់ទីលាន និងផលិតជីកំប៉ុស្តិ៍ដែលមានគុណភាពល្អសម្រាប់ការងារ កសិកម្ម។ គុណសម្បត្តិនៃការធ្វើជីកំប៉ុស្តិ៍ មានជាអាទិ៍៖

- ជំរុញការប្រើប្រាស់វត្ថុធាតុដើមជាសំណល់ឱ្យអស់ពីលទ្ធភាព និងបង្កើតនូវ ផលិតផលជីជំនួសការប្រើប្រាស់ជីគីមីដែលធ្វើឱ្យខូចដល់រចនាសម្ព័ន្ធដី និង សុខភាពមនុស្ស
- ជួយកាត់បន្ថយការសាយភាយឧស្ម័នទីលាន ($NH_4$ & $CO_2$)។
- ជំរុញ និងលើកទឹកចិត្តការផ្លាស់ប្តូរឥរិយាបថនិងផ្នត់គំនិតប្រជាពលរដ្ឋ ឱ្យ ចេះគិតគូរក្នុងការទាញយកប្រយោជន៍ពីសំណល់ គឺឱ្យពួកគាត់មានផ្នត់គំនិត ថ្មី«*សំណល់គឺជាធនធាន*»មិនដូចទស្សនៈដែលថា*សំណល់គឺគ្មានប្រយោជន៍ ដែលត្រូវតែបោះបង់ចោល*។

40




ព័ត៌មានបន្ថែមសូមទំនាក់ទំនង អ៊ីម៉ែល៖ smeydek@yahoo.com

ទូរស័ព្ទ៖ 015 252 737 ឬ 017 252 737

41